**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តព្រៃវែង**

លេខ១៩៥៤/១៧...ពសរ...

# សេចក្តីសម្រេច
# ស្តីពី
# ការរៀបចំ និងប្រព្រឹត្តទៅ នៃគណៈកម្មការដឹកនាំការងារកំណែទម្រង់ របស់រដ្ឋបាលខេត្តព្រៃវែង

## អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើត ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៥/១១២២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការត្រាស់បង្គាប់តែងតាំង អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងារ របស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងសេចក្តីណែនាំលេខ ០២ សណន ចុះថ្ងៃចន្ទ ១២រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការពង្រឹងកិច្ចដំណើរការកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ ។

## សម្រេច

**ប្រការ១:** ត្រូវបានបង្កើតគណៈកម្មការដឹកនាំការងារកំណែទម្រង់របស់រដ្ឋបាលខេត្តព្រៃវែង ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១.ឯកឧត្តម | **ជា សុមេធី** | អភិបាលខេត្ត | ជាប្រធាន |
| ២.ឯកឧត្តម | **ចាន់ ថា** | អភិបាលរងខេត្ត | អនុប្រធានប្រចាំការ |
| ៣.លោក | **អ៊ុយ សាគុណា** | នាយករដ្ឋបាលសាលាខេត្ត | សមាជិក |
| ៤.លោក | **ទួន សុគន្ធ** | ប្រធានមន្ទីរ សេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ៥.លោក | **សឹង សារ៉ាត** | ប្រធានមន្ទីរផែនការខេត្ត | សមាជិក |
| ៦.លោក | **ញ៉ែម សុខជា** | ប្រធានមន្ទីរមុខងារសាធារណៈខេត្ត | សមាជិក |
| ៧.លោកស្រី | **ខិន ស្រីពៅ** | ប្រធានមន្ទីរកិច្ចការនារីខេត្ត | សមាជិក |
| ៨.លោក | **ស៊ិន ចំណាន** | ប្រធានរតនាគារខេត្ត | សមាជិក |
| ៩.លោក | **ប៉ោ ពីឡុត** | នាយកទីចាត់ការផែនការ និងវិនិយោគ | សមាជិក |
| ១០.លោក | **ឈាង សុវណ្ណារ៉ា** | នាយកទីចាត់ការធនធានមនុស្ស | សមាជិក |

| | | | |
|---|---|---|---|
| ១១.លោក | **ប្រាជ្ញ សាវ៉េន** | នាយកទីចាត់រដ្ឋបាល | សមាជិក |
| ១២.លោក | **យស់ ធុល** | នាយកទីចាត់ការហិរញ្ញវត្ថុ | សមាជិក |
| ១៣.លោក | **សេខ សុខជា** | នាយកស្តីទី ទីចាត់ការអន្តរវិស័យ | សមាជិក |
| ១៤.កញ្ញា | **ស៊ិត សុគន្ធារ័ត្ន** | ប្រធានអង្គភាពលទ្ធកម្ម | សមាជិក |
| ១៥.លោក | **ឈុនលី តីរុណា** | ប្រធានអង្គភាពច្រកចេញចូលតែមួយ | សមាជិក |
| ១៦.លោក | **ទេព សុភាព** | ប្រធានការិយាល័យកសាងសមត្ថភាព | សមាជិក |

**ប្រការ២.** គណៈកម្មការដឹកនាំការងារកំណែទម្រង់របស់រដ្ឋបាលខេត្តព្រៃវែង នេះមានតួនាទី និងភារកិច្ចសំខាន់ៗ ដូចខាងក្រោម ៖

- ដឹកនាំសម្របសម្រួលកិច្ចដំណើរការជាទូទៅ នៃការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ស្របតាមច្បាប់ និងលិខិតបទដ្ឋានដែលបានកំណត់
- ដឹកនាំសម្របសម្រួលកិច្ចដំណើរការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ នៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីដាក់បញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលខេត្ត
- ដឹកនាំសម្របសម្រួល គាំទ្រតាមមូលដ្ឋាន ត្រួតពិនិត្យ និងជម្រុញការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ នៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ទំនាក់ទំនងជាមួយក្រសួងស្ថាប័នរដ្ឋ និងមិនមែនរដ្ឋ ដើម្បីសម្របសម្រួល និងកៀរគរការគាំទ្រ ដល់ការអភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល តាមដានត្រួតពិនិត្យ និងផ្តល់អនុសាសន៍ផ្នែករដ្ឋបាល និងបច្ចេកទេសដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- សម្របសម្រួល ដោះស្រាយ បញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- សម្របសម្រួល កៀរគរការចូលរួម និងការគាំទ្រនានា ពីមន្ទីរ អង្គភាពជំនាញ អង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាន និងផ្នែកឯកជនក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហវិមជ្ឈការ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- សម្របសម្រួលការគ្រប់គ្រង និងការធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យនានា ពាក់ព័ន្ធនឹងព័ត៌មាននានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រប់គ្រងមធ្យោបាយ ឧបករណ៍ សម្ភារ និងបរិក្ខានានារបស់ គ.ជ.អ.ប ដែលបានបែងចែកឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗប្រើប្រាស់សម្រាប់ការងារកំណែទម្រង់
- សម្របសម្រួល និងគាំទ្រដល់ការអនុវត្តកម្មវិធីប្រឡងប្រណាំងអំពីការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ក្នុងការដឹកនាំ សម្របសម្រួល ករណីមានការពាក់ព័ន្ធ នឹងសមត្ថកិច្ចរបស់ មន្ទីរ អង្គភាព ទីចាត់ការ ឬថ្នាក់រដ្ឋបាលណាមួយ គណៈកម្មការត្រូវណែនាំដល់មន្ទីរ អង្គភាព ទីចាត់ការ បញ្ជាក់រដ្ឋបាលនោះឱ្យចាត់ចែងអនុវត្តស្របតាមតួនាទី ភារកិច្ចដែលបានកំណត់ ដើម្បីលើកកម្ពស់សមត្ថភាព និងការទទួលខុសត្រូវរបស់ស្ថាប័នដោយមិនត្រូវចាត់ចែងជំនួសឡើយ ហើយត្រូវតាមដានត្រួតពិនិត្យការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័ននោះ

-រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈម នៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ តាមការកំណត់ដើម្បីរាយការណ៍ ជូនគណៈអភិបាលខេត្ត និងក្រុមប្រឹក្សារបស់ខ្លួន ដើម្បីផ្ញើជូនមកលេខាធិការដ្ឋាន គ.ជ.អ.ប ។

**ប្រការ៣:** គណៈកម្មការដឹកនាំការងារកំណែទម្រង់របស់រដ្ឋបាលខេត្តព្រៃវែង មានរបៀបរបបការងារដូចខាងក្រោម៖

-ទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន

-មានរបបប្រជុំជាទៀងទាត់០១(មួយ)ខែម្តង និងប្រជុំតាមការចាំបាច់ ដើម្បីដឹកនាំ សម្របសម្រួល តាមដានត្រួតពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនានា ក្នុងការអនុវត្តការងារកំណែទម្រង់

-ប្រធានគណៈកម្មការ ជាអ្នកកោះប្រជុំ និងជាអធិបតី នៃអង្គប្រជុំរបស់គណៈកម្មការ ករណីប្រធានអវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរទៅឱ្យអនុប្រធាន ជាប្រធានស្តីទី ហើយប្រធានស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតី នៃអង្គប្រជុំ

-កិច្ចប្រជុំរបស់គណៈកម្មការ អាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការទាំងមូល

-ប្រធានគណៈកម្មការអាចអញ្ជើញតំណាងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ប្រធានមន្ទីរ អង្គភាពជំនាញផ្សេងៗ ឬតំណាងអង្គភាពសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា ដើម្បីចូលរួមកិច្ចប្រជុំរបស់គណៈកម្មការ តាមការចាំបាច់

-គ្រប់កិច្ចប្រជុំរបស់គណៈកម្មការត្រូវមានកំណត់ហេតុ ដែលរៀបចំដោយលេខាធិការដ្ឋានរបស់គណៈកម្មការ និងត្រូវចុះហត្ថលេខាដោយអធិបតីអង្គប្រជុំ

-ក្នុងករណីចាំបាច់ គណៈកម្មការអាចស្នើសុំអន្តរាគមន៍ផ្នែកបច្ចេកទេសពីលេខាធិការដ្ឋាន គ.ជ.អ.ប

**ប្រការ៤:** ទីចាត់ការផែនការ និងវិនិយោគខេត្ត ជាលេខាធិការដ្ឋានរបស់គណៈកម្មការដឹកនាំកំណែទម្រង់របស់រដ្ឋបាលខេត្តព្រៃវែង ។ លេខាធិការដ្ឋាននេះស្ថិតក្រោមការដឹកនាំផ្ទាល់ ពីអនុប្រធានប្រចាំការ ។

-ការចំណាយសម្រាប់រៀបចំកិច្ចប្រជុំរបស់គណៈកម្មការ គឺជាបន្ទុករបស់សាលាខេត្តព្រៃវែង ។ ដោយឡែកការចំណាយសម្រាប់ចុះតាមដានត្រួតពិនិត្យ និងផ្តល់អន្តរាគមន៍នានានៅតាមមូលដ្ឋាន គឺជាបន្ទុករបស់អង្គភាពសាមីនីមួយៗ នៃសមាជិកគណៈកម្មការនេះ ។

**ប្រការ៥:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៦:** នាយករដ្ឋបាលសាលាខេត្ត ប្រធានមន្ទីរ-អង្គភាពជំនាញ ពាក់ព័ន្ធ នាយកទីចាត់ការ ប្រធានអង្គភាពចំណុះរចនាសម្ព័ន្ធ សាលាខេត្ត អភិបាលក្រុង អភិបាលស្រុក និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេច នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ...........ខែ...........ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

ព្រៃវែង,ថ្ងៃទី...........ខែ...........ឆ្នាំ២០១៨

**អភិបាលខេត្ត**

ជា_សុវុធគី

<u>កន្លែងទទួល</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-លេខាធិការដ្ឋានគ.ជ.អ.ប

-ក្រុមប្រឹក្សាខេត្ត

-ដូចប្រការ៦ "ដើម្បីអនុវត្ត"

-ឯកសារ